# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ១៣

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានបិទបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សីពីរនាក់ប្រកបដោយប្រសិទ្ធភាព ក៏ប៉ុន្តែ អង្គជំនុំជម្រះត្រូវបង្ខំចិត្តផ្អាកសវនាការកន្លះថ្ងៃមុនពេលកំណត់ ដោយសារតែបញ្ហាសុខភាពរបស់សាក្សីថ្មីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃទី១៩ ខែមីនានេះ។ ពេញមួយសប្តាហ៍នេះ ពុំមានបញ្ហាផ្លូវច្បាប់ ឬនីតិវិធីសំខាន់ៗអ្វីកើតមានឡើងនោះឡើយ ក្រៅតែពីការជំទាស់តិចតួចមួយចំនួនចំពោះការស្នើសុំធ្វើការបង្ហាញការយោងលើភស្តុតាង ដើម្បីជៀសវាងការបង្ហាញភស្តុតាងមិនត្រឹមត្រូវ ឬក៏ការស្នើសុំរបស់អង្គជំនុំជម្រះសាលាដំបូងឲ្យធ្វើការជៀសវាងនូវការតាំងសំណួរច្រំដែល។ សាក្សីដំបូងដែលត្រូវផ្តល់សក្ខីកម្មនាសប្តាហ៍នេះ គឺលោក **នុត នូវ** ដែលជាមេឃុំស្រែរនោងក្នុងឆ្នាំ១៩៧៨។ សក្ខីកម្មរបស់គាត់ បានលើកឡើងពីបទពិសោធន៍របស់គាត់ដែលជាកម្មាភិបាលខ្មែរក្រហមធ្លាប់ធ្វើការក្នុងឃុំចំនួនបីខុសៗគ្នានៃស្រុកត្រាំកក់ ហើយនិងចំណេះដឹងរបស់គាត់ស្តីរចនាសម្ព័ន្ធរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យ ក៏ដូចជា លក្ខខណ្ឌនៃការរស់នៅក្នុងសហករណ៍ផងដែរ។ សាក្សីទីពីរនោះ គឺលោក **វៀល សន** ដែលជាអនុប្រធានមន្ទីរពេទ្យស្រុកត្រាំកក់ ចាប់តាំងពីឆ្នាំ១៩៧៦ ទៅឆ្នាំ១៩៧៩។ គាត់បានផ្តល់ស្តីពីបទពិសោធន៍ និងតួនាទីរបស់គាត់នៅក្នុងមន្ទីរពេទ្យស្រុក ការចូលរួមក្នុងកិច្ចប្រជុំដែលធ្វើការពិភាក្សាកំណត់គោលដៅទៅលើមន្ត្រីរដ្ឋការ **លន់ នល់** ប្រជាជនខ្មែរក្រោម និងជនជាតិភាគតិចវៀតណាម ហើយនិងទំនាក់ទំនងរបស់គាត់ជាមួយនឹង **តាម៉ុក** និងជនជាប់ចោទ លោក **ខៀវ សំផន**។

របាយការណ៍នេះ ក៏បានធ្វើការសង្ខេបផងដែរនូវការបន្តការគ្រប់គ្រងសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង ០០២ វគ្គទី២នេះ ដោយអង្គជំនុំជម្រះបានខិតខំប្រឹងប្រែងធ្វើការថ្លឹងថ្លែងរវាងការដាក់បញ្ចូលឯកសាររបស់ការិយាល័យសហព្រះរាជអាជ្ញានាពេលថ្មីៗនេះពីសំណុំរឿង ០០៣ និង ០០៤ ហើយនិងការស្នើសុំរបស់ក្រុមមេធាវីការពារក្តី ចំពោះការរៀបចំកាលវិភាគថ្មី ដើម្បីផ្តល់លទ្ធភាពក្នុងការត្រួតពិនិត្យលើភស្តុតាងដែលដាក់បញ្ចូលទាំងនោះ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ចូហាន់ណា ហាម៉ាក គីនប៉ហ្គ (Johanna Hamark Kindborg), ហ៊ុយ សម្បូណ៌, ឡូញ ង៉ែត, ដាញ៉ែល ម៉ាតថេស៍ (Daniel Mattes), តាយ លីណា, ហ្វីប៊ី សាប៊ីន (Phoebe Sabin), ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl) និង វង្ស ឧត្តម ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និង ការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដាសម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌ អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះបានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានា ក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University